# រឿង មហាចោរនៅទល់ដែន

**ភាគទី២៤**

លុះសរសេររួចហើយ ព្រះកម្ពុតហុចលិខិតឲ្យទៅនិលពេជ្រ ដែលគេតែងហៅមេកងនិលៗ ប៉ុណ្ណោះឯងៗ ព្រះកម្ពុតបន្ថែមថា៖

- ទៅចាប់អាមានន្ទឲ្យប្រុងប្រយ័ត្នបន្តិច ព្រោះដូចឯងដឹងស្រាប់ហើយ វាក្លាហានណាស់ៗ
- ខ្ញុំព្រះករុណាធ្វើតាមបន្ទូលទានៗ
- តែនិលពេជ្រឯងក៏ជាជើងឯកមួយដែរ បានជាអញបញ្ជូនទៅនេះៗ
- សូមព្រះតេជគុណទុកចិត្តលើខ្ញុំបាទចុះទាន ។ ខ្ញុំបាទសូមរើសយកពលណា ដែលធ្លាប់មានថ្វីដៃបំផុតទៅជាមួយៗ
- អើ ! រើសចុះតាមចិត្ត ទាំងសេះ ទាំងមនុស្ស គ្រឿងប្រដាប់ ឲ្យគ្រប់គ្រាន់ណាៗ
- ព្រះបាទម្ចាស់ៗ

និលពេជ្រ ក៏គំនាប់ព្រះកម្ពុត ហើយស្ទុះចេញទៅៗ ក្នុងពេលនោះ មនុស្សម្នាក់ចាស់ អាយុប្រមាណហុកសិបប្លាយឆ្នាំ តែមាឌនៅរឹងប៉ឹង ដូចក្មេងអាយុម្ភៃឆ្នាំ ចូលមកដល់ៗ គាត់ចាប់អាវនិលពេជ្រ រួចនិយាយថា៖

- ទៅណា ?
- បាទ ! ព្រះតេជគុណ ឲ្យទៅចាប់មានន្ទ លោកតាៗ
- ចូលមកវិញ និយាយគ្នាសិនៗ
- បាទ !

មនុស្សចាស់នេះមានទឹកមុខមាំ ចូលមកដល់ព្រះកម្ពុត ព្រះកម្ពុតឃើញ ក៏ឲ្យអង្គុយកៅអី ដោយគួរសមយ៉ាងគោរព ។ តែមនុស្សចាស់នេះ ទាញកៅអីគ្រាក ដោយគំរិះគំរុះ ទៅកៀនជញ្ជាំង មុខបែរទៅរកបង្អួច ឥតមើលមុខព្រះកម្ពុតឡើយ ។ ព្រះកម្ពុតប្រឹងពន្យល់ ថា៖

- សូមលោកជ្រាប គួរអីព្រហើនម្ល៉េះ ?

អត្ថបទដោយ៖ មាស សុភាព

- ព្រហើនអី ?
- បាទ ទាន ! វាលួចការប្រពន្ធឥតឲ្យខ្ញុំដឹង។
- ដឹងទៅបានការអី ?
- បាទទេ ! ខ្ញុំជាឪពុកវា គួរតែវាប្រាប់ខ្ញុំមុននឹងសម្រេចការអ្វីនីមួយៗ។
- វាដឹងថា លោកមិនធ្វើតាមវាពិត បានជាវាមិនប្រាប់ ។ ឈប់និយាយ ! ចុះឥឡូវលោកធ្វើអ្វី ?
- ខ្ញុំឲ្យទាហានទៅចាប់វាមក។
- លោកជាឪពុក លោកធ្លាប់ស្គាល់ខ្ញុំជានិច្ចរៀងដរាបមក។ ខ្ញុំស្រលាញ់លោកចិត្តមួយ ថ្លើមមួយ។ ខ្ញុំចាស់ហើយ តែខ្ញុំធ្លាប់គប់

ប្រទះ នឹងរឿងរ៉ាវច្រើនណាស់ ខ្ញុំដឹងរឿងអស់នោះ ។ ខ្ញុំជាទីប្រឹក្សា របស់គ្រប់ចៅហ្វាយខេត្តទាំងអស់ ដែលមានចំនួនបួននាក់ មកហើយ គឺ មានលោកនេះជាក្រោយបង្អស់។ ខ្ញុំសូម កុំឲ្យលោកចាត់ទៅចាប់វា ធ្វើអ្វី។ តាមខ្ញុំយល់ គឺគួរបង្រួញរឿងនេះ ឲ្យខ្លី កុំពង្រីក ឲ្យវែងទៅៗនោះ។

- ចុះ ឲ្យខ្ញុំធ្វើយ៉ាងណាវិញ ?
- មានន្ទវាមានទៅណា វាជាកូនលោកស្រាប់ តែបន្តិចទៀតវាមកវិញហើយ។ ចាំបាច់ទៅព័ទ្ធចាប់វាធ្វើអ្វី ?
- សូមទោស គិរីមេរុ ឥឡូវព្រះកម្ពុត ចាត់ការនេះហើយ ព្រះកម្ពុតមិនអាចដកពាក្យទេ ។ ខ្ញុំស្គាប់លោកជានិច្ច ខ្ញុំគោរពលោក

ជានិច្ច តែក្នុងពេលនេះ ខ្ញុំត្រូវតែផ្ដន្ទាទោសអាមានន្ទ ឲ្យអស់ចិត្តខ្ញុំខឹង។ ខ្ញុំខឹងណាស់ សូមប្រាប់លោកឲ្យត្រង់។ ទៅនិលពេជ្រទៅ!

និលពេជ្រ ក៏ចេញទៅតាមពាក្យព្រះកម្ពុត។ តាគិរីសុមេរុ ពេបមាត់ សម្ងឹងមើលក្ដារ ឥតនិយាយមួយមាត់។ តាគិរីសុមេរុនេះ ជាអ្នកចម្បាំងដើងចាស់ ដែលរស់ប្រាំរាជស្ដេច មកហើយ។ គាត់គ្មានខ្លាចអ្នកណាទេ ទោះព្រះកម្ពុត ក៏គ្មានខ្លាចដែរ។ តែព្រះកម្ពុត គោរពគាត់ជា

ចាស់ទុំដរាបៗ កាលព្រះកម្ពុតនៅក្មេង គាត់បានចិញ្ចឹមបីបាច់រក្សា រួចក្នុងសង្គ្រាមនានា គាត់បានជួយជីវិតព្រះកម្ពុតនេះ ឲ្យរួចពីក្ដីមរណៈ ជាច្រើនលើក ច្រើនគ្រាៗ ដើម្បីតបស្នង សងគុណតាគិរីសុមេរុវិញ ព្រះកម្ពុត បានអញ្ជើញគាត់ ឲ្យមកនៅជាមួយៗ គិរីសុមេរុ ជាមនុស្សមានបញ្ញាវៃឆ្លាត ហើយពូកែស្ទិតស្ទាញ ខាងកាន់គ្រឿងអាវុធ រកអ្នកណាមួយ ប្រៀបផ្ទឹមពុំបានឡើយៗ គិរីសុមេរុ គ្រាកឈរប្រាននកៅអីដួលផ្កាប់ផ្ងារ រួចដើរចេញទៅខាងក្រៅៗ ព្រះកម្ពុតមានសេចក្ដីបារម្ភ នឹងអាកប្បកិរិយានេះដែរ តែដឹងចិត្តតាគិរីសុមេរុ ...ៗ ទោះជាយ៉ាងណាក៏បុគ្គលនេះជាមនុស្សផុតចាប់ទោសអូសដំណើរដែរៗ ព្រះកម្ពុតមុខឡើងស្វាំងអង្វរថា៖

- អញ្ជើញលោកតាពិសាតែសិន!

គិរីសុមេរុស្រលាញ់មាននុ្ទណាស់ ហេតុនេះហើយបានជាគាត់ មិនចង់ឲ្យព្រះកម្ពុត តាមរកមានន្ទនោះៗ លុះដើរចេញមក ដល់ក្រៅបន្ទាយ គាត់ក្រលេកមើលនាយអាយ រួចស្ទុះទៅចាប់ស្មានាយកោប ជាប់ពីក្រោយៗ

- លោកតាៗ ! សួស្ដីលោកតា !
- អាចំកួត មានន្ទទៅណាហើយ ?
- បាទ ! ខ្ញុំបាទមិនដឹងដែរៗ
- ចុះម្ដេចអាឯង នៅប៉ែលប៉ោលទីនេះទៀត ?
- ឲ្យខ្ញុំធ្វើយ៉ាងណាលោកតា ?
- អាឯងឆ្កួត ឬជា ?
- បាទ ! ជាលោកតា!
- អាឯងស្រលាញ់មានន្ទ ទេ ?
- ស្រលាញ់ដែរ!
- មានន្ទមានទុក្ខ ម្ដេចអាឯងសប្បាយនៅនេះ?
- បើដូច្នេះ ខ្ញុំទៅរកឥឡូវៗ
- អើ ! ទៅ ! ទៅប្រាប់វាថា គេតាមចាប់ ឲ្យប្រយ័ត្នខ្លួន . . .ៗ

អត្ថបទដោយ៖ មាស សុភាព

- បាទ !
- ឯងដឹងមានន្ទនៅឯណាទេ ?
- ទេ !
- បើឯងមិនដឹងធ្វើម្តេច ទៅរកឃើញ ?
- ការនេះស្រេចនៅលើខ្ញុំ ខ្ញុំជ្រែកដីវាទឹក កកូរអាកាសរកទាល់តែឃើញហ្នឹង។ យ៉ ! វាទៅណា កំបាំងភ្នែកអាកោប។

គិរីសុមេរុ សើចទះស្មានាយកោប៖

- ប្រយ័ត្នតែឯងមិនឃើញវិញ តើឲ្យអញធ្វើម៉េច ?
- ឲ្យពុះក្បាលកោបជាប្រាំពីភាគ។
- បីភាគបានទេ ?
- តិចណាស់ មិនស្ដាប់កោបទេ កោបធ្លាប់ទទួលប្អូនរួចមកហើយ ៗឥតអី។
- បើដូច្នោះ អញសុំតែមួយសិនបានទេ ?
- គ្នាឯង អ្នកណាដែលឲ្យលេងអញ្ចឹង។
- អាកោប អញសួរឯងបន្តិចបានទេ ?
- បាន ! យី ! លោកតាសួរចុះ សួររឿងព្រះ ឬរឿងជាតិ ឬរឿងព្រះឥសូរ . . . ។
- អើ ! កាលណាបានឯងយកប្រពន្ធ ?
- ដល់លោកតាយក បានខ្ញុំយកដែរ។
- ហាស ៗ អាចំកួត!
- ទៅគិតអីរឿងប្រពន្ធកូននោះ?
- ចុះឯងគិតអីវិញ ?
- រឿងជាតិ!
- អូ ! អាខ្មោច លោជា ឯងចេះគិតពីរឿងជាតិដែរ។
- យី ! សិស្សមានន្ទណ៎ា ខ្ញុំ!

អត្ថបទដោយ៖ មាស សុភាព

- ឱ ! ឯងបេះគិតជាតិ ព្រោះឯងជាសិស្សគេទេឬ ?
- ឱស ៗ តែ ខ្ញុំគិតរឿងជាតិ ព្រោះខ្ញុំជាខ្មែរ។
- បើអញ្ចឹងទៅចុះ!

នាយកោបហួច ព្ទស្វូររើតៗ។ សេះមួយ កញ្ឆៀវឯចម្ងាយ។ មិនយូរប៉ុន្មាន សេះនេះលូនមក ដល់ ពីមុខនាយកោបភ្ជាម ដែលស្ទុះទៅយកអាន និង បង្ហៀរមកដាក់ ដោយរួសរាន់។ តាគិរីសុមេរុឃើញយ៉ាងនេះ មានចិត្តស្ញើចនាយកោបមួយអន្ទើដែរ តែពុំចេញស្តីអ្វី ឲ្យវាដឹងចិត្តគាត់ឡើយ។ នាយកោបស្ទុះលោតក្វែត ឡើងលើខ្នងសេះ គំនាប់តាគិរីយ៉ាងគួរសម រួចបំផាយសេះ ទៅខាងទិសមង្គលបុរី ទៅ។ តាគិរីឈរមើលសេះនាយកោប ដោយញញឹមគ្មានដាច់ ទាល់តែបាត់ព្ទស្វូរដើង ទើបឈប់មើល។ បន្ទាប់ក្រោយពីនេះបន្តិច ហ្វូងសេះរបស់និលពេជ្រ ក៏ចេញដំនើរតាមយ៉ាងកក្រើកដី នាំឲ្យរាត្រីនោះ រន្ធត់ញាប់ញ័រជាពន់ពេក៕

(សូមរង់ចាំតាមដានភាគទី២៩ នៅសប្តាហ៍ក្រោយ)

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយៈ មាស សុភាព